**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តសៀមរាប**
**តុលាការរដ្ឋប្បវេណី**
សំណុំរឿងរដ្ឋប្បវេណីលេខៈ ១៧០
ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២១
សាលក្រមរដ្ឋប្បវេណីលេខៈ ២៤(ក)/៣២៩
ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១

**សាលក្រម**
**ក្នុងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តសៀមរាប**

បានធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ
នៅសាលសវនាការលេខៈ ក២ នៃសាលាដំបូងខេត្តសៀមរាប
បានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ៈថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១
កាលបរិច្ឆេទប្រកាសសាលក្រមៈ ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១

**ចៅក្រមជំនុំជម្រះ**

ឯកឧត្តម [redacted] ឋានៈ ប្រធានសាលាដំបូង

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ឋានៈ ក្រឡាបញ្ជី

**ដើមចោទៈ**

ធនាគារ[redacted] ក.អ មានអាសយដ្ឋានអគារលេខ [redacted] ដែលមានឈ្មោះ[redacted] រដ្ឋា ជាតំណាង។

អ្នកតំណាងដោយអាណត្តិៈ លោកមេធាវី [redacted] អត្តលេខ ១៨០៩, កញ្ញាមេធាវី [redacted] អត្តលេខ ២១៤៤T, កញ្ញាមេធាវី [redacted] អត្តលេខ ១៥៥២, លោកមេធាវី [redacted] អត្តលេខ ៧៥៤ និងលោកមេធាវី [redacted] អត្តលេខ ២១៧២T មានអាសយដ្ឋានអគារលេខ[redacted]។

**សហចុងចម្លើយៈ**

១-ឈ្មោះ [redacted] រ៉ាណូ ភេទប្រុស កើតឆ្នាំ១៩៨៧ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ [redacted] ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១២ អាសយដ្ឋានស្ថិតនៅ[redacted]។

២-ឈ្មោះ [redacted] ស្រីតូច ភេទស្រី កើតឆ្នាំ១៩៩០ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ១៨០៤៨០០៣៥(០១) ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៦ អាសយដ្ឋានស្ថិត[redacted]។

**ក-ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញៈ**

១-បង្គាប់ឲ្យសហចុងចម្លើយរួមគ្នាសងប្រាក់ដើមចំនួន ៣០.៤៩៦,១១$(សាមសិបពាន់បួនរយកៅសិបប្រាំមួយដុល្លារអាមេរិក និងដប់មួយសេន)ឲ្យមកដើមចោទ។

២-បង្គាប់ឲ្យសហចុងចម្លើយបង់ការប្រាក់តាមអត្រា ១២%(ដប់ពីរភាគរយ)ក្នុងមួយឆ្នាំ នៃប្រាក់ដើមចំនួន ៣០.៤៩៦,១១$(សាមសិបពាន់បួនរយកៅសិបប្រាំមួយដុល្លារអាមេរិក និងដប់មួយសេន) គិតចាប់



Scanned with CamScanner

ពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ រហូតដល់ថ្ងៃសងរួចគ្រប់ចំនួន ឲ្យមកដើមចោទ។

៣-បង្គាប់ឲ្យសហចុងចម្លើយបង់ប្រាក់ការពិន័យ តាមអត្រាស្មើនឹង២(ពីរ)ដងនៃអត្រាការប្រាក់ដែលមានចែងក្នុងកិច្ចសន្យាខ្ចីបរិភោគលេខ ៣៩៤/២០១៨ ឥ.ទ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ លើប្រាក់ដើមចំនួន ៣០.៤៩៦,១១$(សាមសិបពាន់បួនរយកៅសិបប្រាំមួយដុល្លារអាមេរិក និងដប់មួយសេន) គិតចាប់ពីថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៩ រហូតដល់ថ្ងៃសងរួចគ្រប់ចំនួន ឲ្យមកដើមចោទ។

៤-បង្គាប់ឲ្យសហចុងចម្លើយបង់សេវាកម្មច្បាប់ និងការខាតបង់ពេលវេលាចំនួន ៥.០០០$(ប្រាំពាន់ដុល្លារអាមេរិក) ឲ្យមកដើមចោទ។

៥-បង្គាប់ឲ្យសហចុងចម្លើយជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្ដី។

៦-សាលក្រមនេះអាចអនុវត្តបណ្ដោះអាសន្នបានត្រង់ចំណុចទី១, ទី២ និងទី៣ ខាងលើ។

**ខ-ដំណើររឿងក្ដី និង ចំណុចវិវាទ**

**ខ-១-ការសង្ខេបអំពីរឿងក្ដី**

នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ សហចុងចម្លើយឈ្មោះ [redacted] វ៉ាណូ និងឈ្មោះ [redacted] ស្រីតូច បានខ្ចីប្រាក់ពីដើមចោទនូវទឹកប្រាក់ចំនួន ៣៥.០០០$(សាមសិបប្រាំពាន់ដុល្លារអាមេរិក) ដូចមាននៅក្នុងកិច្ចសន្យាខ្ចីបរិភោគលេខ ៣៩៤/២០១៨ ឥ.ទ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ ដោយកំណត់រយៈពេលខ្ចីចំនួន ៦០(ហុកសិប)ខែ តាមអត្រាការប្រាក់ ១២%(ដប់ពីរភាគរយ)ក្នុងមួយឆ្នាំ រួមនិងសំណងនៃការខូចខាត(ប្រាក់ពិន័យ)ស្មើនឹង២(ពីរ)នៃអត្រាការប្រាក់ក្នុងកាលកំណត់។ នៅក្នុងការខ្ចីប្រាក់នេះសហចុងចម្លើយបានដាក់នូវទ្រព្យសម្បត្តិដើម្បីជានាបំណុល ដូចមាននៅក្នុងកិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំ ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៨។

**ខ-២-អង្គហេតុដែលគ្មានវិវាទ**

ដើមចោទ និងសហចុងចម្លើយបានព្រមព្រៀងគ្នាបង្កើតកិច្ចសន្យាខ្ចីបរិភោគលេខ ៣៩៤/២០១៨ ឥ.ទ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ ដោយសហចុងចម្លើយជាភាគីអ្នកខ្ចី បានខ្ចីប្រាក់ពីដើមចោទជាភាគីអ្នកឲ្យខ្ចី នូវទឹកប្រាក់ចំនួន ៣៥.០០០$(សាមសិបប្រាំពាន់ដុល្លារអាមេរិក)។ ការខ្ចីប្រាក់នេះ សហចុងចម្លើយត្រូវបង់ប្រាក់តាមតារាងរំលស់ប្រាក់ដើម និងការប្រាក់។ បន្ទាប់ពីទទួលបានប្រាក់គ្រប់ចំនួនពីដើមចោទហើយ សហចុងចម្លើយបានបង់រំលស់ប្រាក់ដើមឲ្យទៅដើមចោទបានមួយចំនួន ដែលធ្វើឲ្យប្រាក់ដើមដែលសហចុងចម្លើយនៅជំពាក់មានចំនួន ៣០.៤៩៦,១១$(សាមសិបពាន់បួនរយកៅសិបប្រាំមួយដុល្លារអាមេរិក និងដប់មួយសេន)។

ដើមចោទ និងសហចុងចម្លើយបានព្រមព្រៀងគ្នាកំណត់ការប្រាក់តាមអត្រា ១២%(ដប់ពីរភាគរយ) ក្នុងមួយឆ្នាំ ដោយកំណត់រយៈពេលខ្ចីចំនួន ៦០(ហុកសិប)ខែ គិតចាប់ពីថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៨ រហូតដល់ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៤។ សហចុងចម្លើយបានខកខានក្នុងការបង់ការប្រាក់ទៅឲ្យដើមចោទ គិតចាប់ពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩។

ដើមចោទ និងសហចុងចម្លើយបានព្រមព្រៀងគ្នាកំណត់ជាមុននូវសំណងនៃការខូចខាត តាមអត្រាស្មើនឹង២(ពីរ)ដងនៃអត្រាការប្រាក់នៃប្រាក់ដើម ក្នុងករណីដែលសហចុងចម្លើយខកខានបង់ប្រាក់ដើម និងការប្រាក់តាមតារាងរំលស់ប្រាក់ដើម និងការប្រាក់។

**ខ-៣-ចំណុចវិវាទ**

ដើមចោទទាមទារឲ្យសហចុងចម្លើយបង់សេវាកម្មច្បាប់ និងការខាតបង់ពេលវេលា ចំនួន ៥.០០០$



Scanned with CamScanner

(ប្រាំពាន់ដុល្លារអាមេរិក) សហចុងចម្លើយមិនទទួលស្គាល់នូវការទាមទារ។

**ខ-៤-ការអះអាងរបស់ដើមចោទ:**

លោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឲ្យដើមចោទធនាគារ [redacted] បានធ្វើសេចក្តីថ្លែងការណ៍ថា: ដើមចោទសុំរក្សាការទាមទារដូចមាននៅក្នុងពាក្យបណ្តឹង ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២១ និងសេចក្តីថ្លែងការណ៍ដែលមាននៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី៣០ខែមិថុនា ឆ្នាំ២០២១ ដោយមូលហេតុនៃការទាមទារមានដូចខាងក្រោម:

ការទាមទារចំណុចទី១

សហចុងចម្លើយឈ្មោះ [redacted] រ៉ាណូ និងឈ្មោះ [redacted] ស្រីតូច បានព្រមព្រៀងខ្ចីប្រាក់ពីដើមចោទ ដូចមាននៅក្នុងកិច្ចសន្យាខ្ចីបរិភោគលេខ ៣៩៤/២០១៨ ឥ.ទ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ ដែលមានទឹកប្រាក់សរុបចំនួន ៣៥.០០០$(សាមសិបប្រាំពាន់ដុល្លារអាមេរិក)។ បន្ទាប់ពីសហចុងចម្លើយទទួលបានប្រាក់គ្រប់ចំនួនពីដើមចោទហើយ សហចុងចម្លើយត្រូវបង់ប្រាក់តាមតារាងរំលស់ប្រាក់ដើម និងការប្រាក់។ នៅក្នុងការអនុវត្តកិច្ចសន្យានេះ សហចុងចម្លើយបានបង់ការប្រាក់ និងប្រាក់ដើមមកឲ្យដើមចោទបានមួយចំនួន ដែលធ្វើឲ្យប្រាក់ដើមដែលសហចុងចម្លើយនៅជំពាក់មានចំនួន ៣០.៤៩៦,១១$(សាមសិបពាន់បួនរយកៅសិបប្រាំមួយដុល្លារអាមេរិក និងដប់មួយសេន)។ ម្យ៉ាងទៀត ដើមចោទបានចេញលិខិតរំលឹកឲ្យសងប្រាក់ទៅសហចុងចម្លើយជាច្រើនលើក ក៏សហចុងចម្លើយនៅតែមិនអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យាដដែល។ នៅក្នុងការខ្ចីប្រាក់នេះ សហចុងចម្លើយក៏បានដាក់នូវទ្រព្យសម្បត្តិដើម្បីធានាបំណុល ដូចមាននៅក្នុងកិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំ ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៨។

ហេតុដូច្នេះ ទើបដើមចោទស្នើសុំឲ្យតុលាការសម្រេចបង្គាប់ឲ្យសហចុងចម្លើយសងប្រាក់ដើមចំនួន ៣០.៤៩៦,១១$(សាមសិបពាន់បួនរយកៅសិបប្រាំមួយដុល្លារអាមេរិក និងដប់មួយសេន)មកឲ្យខ្លួន។

ការទាមទារចំណុចទី២

នៅក្នុងការខ្ចីប្រាក់នេះ សហចុងចម្លើយ និងដើមចោទបានព្រមព្រៀងគ្នាកំណត់ការប្រាក់តាមអត្រា ១២%(ដប់ពីរភាគរយ)ក្នុងមួយឆ្នាំ ដោយកំណត់រយៈពេលសងចំនួន ៦០(ហុកសិប)ខែ គិតចាប់ពីថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៨ រហូតដល់ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៤ ដូចមានកំណត់នៅក្នុងកិច្ចសន្យាខ្ចីបរិភោគលេខ ៣៩៤/២០១៨ ឥ.ទ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ នៅត្រង់ប្រការ២ ចំណុច២.៣ និងឧបសម្ព័ន្ធនៃកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ ត្រង់ចំណុច១។ នៅក្នុងការបង់ការប្រាក់នេះ សហចុងចម្លើយបានបង់ការប្រាក់ឲ្យមកដើមចោទបានមួយចំនួន លុះដល់ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ រហូតមកដល់ពេលនេះ សហចុងចម្លើយមិនបានបង់ការប្រាក់មកឲ្យដើមចោទទៀតនោះទេ។ ហេតុនេះ ទើបដើមចោទទាមទារឲ្យសហចុងចម្លើយបង់ការប្រាក់តាមអត្រា ១២%(ដប់ពីរភាគរយ)ក្នុងមួយឆ្នាំ នៃប្រាក់ដើមចំនួន ៣០.៤៩៦,១១$(សាមសិបពាន់បួនរយកៅសិបប្រាំមួយដុល្លារអាមេរិក និងដប់មួយសេន) គិតចាប់ពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ រហូតដល់ថ្ងៃសងរួចគ្រប់ចំនួន។

ការទាមទារចំណុចទី៣

នៅក្នុងការខ្ចីប្រាក់នេះដែរ សហចុងចម្លើយ និងដើមចោទបានព្រមព្រៀងគ្នាជាមុនដោយកំណត់នូវសំណងនៃការខូចខាត តាមអត្រាស្មើនឹង២(ពីរ)ដងនៃអត្រាការប្រាក់ នៃប្រាក់ដើម ក្នុងករណីដែលសហចុងចម្លើយខកខានបង់ការប្រាក់ និងប្រាក់ដើមទៅឲ្យដើមចោទ។ តាមរយៈការព្រមព្រៀងនេះ ឃើញថា



Scanned with CamScanner

សហចុងចម្លើយពិតជាមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្នុងការសងប្រាក់មកឲ្យដើមចោទនោះទេ ដែលជាហេតុធ្វើឲ្យដើមចោទប្តឹងទាមទារឲ្យសហចុងចម្លើយបង់សំណងនៃការខូចខាត តាមអត្រាស្មើនឹង២(ពីរ) ដងនៃអត្រាការប្រាក់ នៃប្រាក់ដើមចំនួន ៣០.៤៩៦,១១$(សាមសិបពាន់បួនរយកៅសិបប្រាំមួយដុល្លារអាមេរិក និងដប់មួយសេន) គិតចាប់ពីថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៩ រហូតដល់ថ្ងៃសងរួចគ្រប់ចំនួន ដោយយោងតាមការកំណត់នៅក្នុងឧបសម្ព័ន្ធនៃកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ នៅត្រង់ចំណុច ៧.១ ដែលចែងពីបំណុលហួសកាលកំណត់ត្រូវរងនូវការផាកពិន័យស្មើនឹងចំនួន ២(ពីរ) ដងនៃអត្រាការប្រាក់ក្នុងកាលកំណត់នីមួយៗ។

ការទាមទារចំណុចទី៤

ដើមចោទទាមទារឲ្យសហចុងចម្លើយបង់សេវាកម្មផ្លូវច្បាប់ និងការខាតបង់ពេលវេលាចំនួន ៥.០០០$ (ប្រាំពាន់ដុល្លារអាមេរិក) ដោយសារតែសហចុងចម្លើយជាអ្នកមានកំហុស ដែលមិនអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យា ទោះបីជាដើមចោទបានជូនដំណឹងទៅសហចុងចម្លើយដើម្បីឲ្យអនុវត្តកាតព្វកិច្ចក៏ដោយ ក៏សហចុងចម្លើយនៅតែមិនអនុវត្តកាតព្វកិច្ចដដែល ហើយការបំពានកាតព្វកិច្ចនេះដែរធ្វើឲ្យលំហូរសាច់ប្រាក់របស់ដើមចោទមានការកកស្ទះ តាំងពីថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៩ មក។ តាមឧបសម្ព័ន្ធកិច្ចសន្យាខ្ចីបរិភោគលេខ ៣៩៤/២០១៨ ឥ.ទ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ ត្រង់ចំណុច៧.៥ និងចំណុច៨.៣ បានកំណត់ថា ករណីមានបណ្តឹងទាមទារសហចុងចម្លើយយល់ព្រមទទួលខុសត្រូវលើការចំណាយសម្រាប់នីតិវិធីនៃបណ្តឹង និងសោហ៊ុយចំណាយមេធាវី រួមទាំងសោហ៊ុយចំណាយផ្សេងៗទៀតទាំងអស់ជូនដើមចោទ។

ការទាមទារចំណុចទី៥

ដើមចោទសុំទាមទារឲ្យសហចុងចម្លើយទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តី និងប្រាក់បង់ពន្ធផ្សេងៗ ដោយសារតែសហចុងចម្លើយមិនអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យាក្នុងការបង់ប្រាក់មកឲ្យដើមចោទ ទើបឈានទៅដល់ការដាក់ពាក្យបណ្តឹង ហើយការដាក់ពាក្យបណ្តឹងនេះគឺទាមទារឲ្យមានការបង់ពន្ធ ហេតុនេះការទទួលបន្ទុកបង់ពន្ធត្រូវតែជាបន្ទុករបស់ភាគីសហចុងចម្លើយ។

ការទាមទារចំណុចទី៦

គឺដោយសារតែសហចុងចម្លើយមិនអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យា ម្យ៉ាងទៀតកិច្ចសន្យាខ្ចីបរិភោគលេខ ៣៩៤/២០១៨ ឥ.ទ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ មានភាពច្បាស់លាស់ ក៏ដូចជាមានការដាក់ធានាទ្រព្យចំពោះបំណុលផងដែរ និងដើម្បីកុំឲ្យមានការអូសបន្លាយនីតិវិធីតទៅមុខទៀត ហើយម្យ៉ាងទៀតរឿងក្តីនេះក៏មានគោលបំណងសងជាប្រាក់ ហើយសហចុងចម្លើយក៏បានដាក់ធានានូវអចលនវត្ថុ ដូចមានចែងក្នុងកិច្ចសន្យាបង្កើតសិទ្ធិបញ្ចាំ ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៨។ ម្យ៉ាងទៀតមានភាពចាំបាច់ណាស់សម្រាប់ធនាគារក្នុងនាមជាស្ថាប័នរកចំណូលតាមរយៈការបង្វិលសាច់ប្រាក់ ដូច្នេះ ធនាគារមិនអាចឲ្យបំណុលនេះកកស្ទះបន្តទៀតទេ ឬមិនអាចធ្វើការទាមទារក្នុងរយៈពេលយូរបាន។ ហេតុដូច្នេះ ការស្នើសុំអនុវត្តជាបណ្តោះអាសន្ន គឺស្របទៅនឹងមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ទើបដើមចោទទាមទារឲ្យតុលាការចេញសាលក្រមដែលមានអានុភាពអនុវត្តជាបណ្តោះអាសន្ននៅត្រង់ចំណុចទី១, ទី២ និងទី៣។

**ខ-៥-ការអះអាងរបស់សហចុងចម្លើយ:**

ឈ្មោះ [redacted] ស្រីតូច ជាសហចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍តបថា:

ការទាមទារចំណុចទី១



Scanned with CamScanner

កាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ ខ្លួននិងឈ្មោះ [redacted] រ៉ាណូ បានព្រមព្រៀងខ្ចីប្រាក់ពីដើមចោទ ដូចមាននៅក្នុងកិច្ចសន្យាខ្ចីបរិភោគលេខ ៣៩៤/២០១៨ ត.ទ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ ដែលមានទឹកប្រាក់សរុបចំនួន ៣៥.០០០$(សាមសិបប្រាំពាន់ដុល្លាអាមេរិក)។ បន្ទាប់ពីទទួលបានប្រាក់គ្រប់ចំនួនពីដើមចោទហើយ ខ្លួនត្រូវបង់ប្រាក់តាមតារាងរំលស់ប្រាក់ដើម និងការប្រាក់។ នៅក្នុងការអនុវត្តកិច្ចសន្យានេះ ខ្លួនបានបង់ការប្រាក់ និងប្រាក់ដើមទៅឲ្យដើមចោទបានមួយចំនួន ដែលធ្វើឲ្យប្រាក់ដើមដែលខ្លួននៅជំពាក់មានចំនួន ៣០.៤៩៦,១១$(សាមសិបពាន់បួនរយកៅសិបប្រាំមួយដុល្លាអាមេរិក និងដប់មួយសេន)។ ចំពោះការទាមទារប្រាក់ដើមរបស់ដើមចោទនេះ ខ្លួនទទួលស្គាល់នូវការទាមទារនេះ។

ការទាមទារចំណុចទី២

នៅក្នុងការខ្ចីប្រាក់នេះ ខ្លួន និងដើមចោទពិតជាបានព្រមព្រៀងគ្នាកំណត់ការប្រាក់តាមអត្រា ១២% (ដប់ពីរភាគរយ)ក្នុងមួយឆ្នាំ ដោយកំណត់រយៈពេលសងចំនួន ៦០(ហុកសិប)ខែ គិតចាប់ពីថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៨ រហូតដល់ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៤ ដូចមានកំណត់នៅក្នុងកិច្ចសន្យាខ្ចីបរិភោគលេខ ៣៩៤/២០១៨ ត.ទ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ ។ នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ រហូតមកដល់ពេលនេះ ខ្លួនពិតជាបានខកខានបង់ការប្រាក់ទៅឲ្យដើមចោទប្រាកដមែន។

ការទាមទារចំណុចទី៣

នៅក្នុងការខ្ចីប្រាក់នេះដែល ខ្លួនពិតជាបានព្រមព្រៀងគ្នាកំណត់ជាមុននូវសំណងនៃការខូចខាត តាមអត្រាស្មើនឹង២(ពីរ)ដងនៃអត្រាការប្រាក់ នៃប្រាក់ដើមប្រាកដមែន នៅក្នុងករណីដែលខ្លួនមានការខកខានមិនបានបង់ប្រាក់ដើម និងការប្រាក់តាមតារាងរំលស់ប្រាក់ដើម និងការប្រាក់។ ហេតុនេះ ការទាមទាររបស់ដើមចោទ ដែលសុំឲ្យខ្លួនបង់ប្រាក់ពិន័យក្នុងអត្រាស្មើនឹង២(ពីរ)ដងនៃអត្រាការប្រាក់ដែលមានចែងក្នុងកិច្ចសន្យាខ្ចីបរិភោគលេខ ៣៩៤/២០១៨ ត.ទ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ នៃប្រាក់ដើមចំនួន ៣០.៤៩៦,១១$(សាមសិបពាន់បួនរយកៅសិបប្រាំមួយដុល្លាអាមេរិក និងដប់មួយសេន) គិតចាប់ពីថ្ងៃដែលខ្លួនខកខាននោះ ខ្លួនទទួលស្គាល់នូវការទាមទារនេះផងដែរ។

ការទាមទារចំណុចទី៤ ទី៥ និងទី៦

ខ្លួនសុំប្រានចោលនូវការទាមទារនូវចំណុចខាងលើនេះ ដោយស្នើសុំឲ្យដើមចោទ ដកការទាមទារនូវចំណុចខាងលើនេះ ដោយសារតែបច្ចុប្បន្នខ្លួនមិនមានលទ្ធភាពក្នុងការរកប្រាក់ សម្រាប់សងជូនទៅដើមចោទនោះទេ។ ម្យ៉ាងទៀត ខ្លួនកំពុងដំណើរលក់ដី ប៉ុន្តែដោយសារបញ្ហាកូវីតនេះ ទើបធ្វើឲ្យខ្លួនមិនអាចលក់ដីដាច់នោះទេ ហើយខ្លួនក៏មិនមានចេតនាក្នុងការគេចវេសមិនសងប្រាក់ទៅធនាគារនោះដែរ។

## ការសំអាងហេតុ

ពាក្យបណ្ដឹងអង្គសេចក្ដី ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២១ របស់ដើមចោទ ធនាគា[redacted] ដែលមានឈ្មោះ [redacted] រដ្ឋា ជាតំណាង តុលាការអាចលើកយកមកធ្វើការទាញហេតុផលដោយផ្ទាល់មាត់បានតាមបញ្ញត្តិមាត្រា ៩ និងមាត្រា ២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

តាមសេចក្ដីថ្លែងការណ៍របស់អ្នកតំណាងដោយអាណត្តិឲ្យដើមចោទ, សហចុងចម្លើយឈ្មោះ [redacted] ស្រីតូច រួមនឹងការពិនិត្យភស្តុតាងជាឯកសារដែលមានក្នុងសំណុំរឿងឃើញថា:

**ក-ការវិនិច្ឆ័យចំពោះចំណុចវិវាទ**

ដើមចោទទាមទារឲ្យសហចុងចម្លើយបង់ប្រាក់សេវាកម្មច្បាប់ និងការខាតបង់ពេលវេលា ចំនួន ៥.០០០$(ប្រាំពាន់ដុល្លាអាមេរិក)



Scanned with CamScanner

ដោយសារតែសហចុងចម្លើយជាអ្នកមានកំហុស ដែលមិនអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យា ទោះបីជាដើមចោទបានជូនដំណឹងទៅសហចុងចម្លើយដើម្បីឲ្យអនុវត្តកាតព្វកិច្ចក៏ដោយ ក៏សហចុងចម្លើយនៅតែមិនអនុវត្តកាតព្វកិច្ចដដែល ហើយការបំពានកាតព្វកិច្ចនេះដែរធ្វើឲ្យលំហូរសាច់ប្រាក់របស់ដើមចោទមានការកកស្ទះ តាំងពីថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៩ មក។ តាមឧបសម្ព័ន្ធកិច្ចសន្យាខ្ចីបរិភោគលេខ ៣៩៤/២០១៨ ឥ.ទ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ ត្រង់ចំណុច៧.៥ និងចំណុច៨.៣ បានកំណត់ថា ករណីមានបណ្ដឹងទាមទារ សហចុងចម្លើយយល់ព្រមទទួលខុសត្រូវលើការចំណាយសម្រាប់នីតិវិធីនៃបណ្ដឹង និងសោហ៊ុយចំណាយមេធាវី រួមទាំងសោហ៊ុយចំណាយផ្សេងៗទៀតទាំងអស់ជូនដើមចោទ។ សហចុងចម្លើយអះអាងមិនទទួលស្គាល់តាមការទាមទាររបស់ដើមចោទនោះទេ។

តាមការអះអាងខាងលើនេះ នឹងការពិនិត្យភស្តុតាងជាកិច្ចសន្យាខ្ចីបរិភោគលេខ ៣៩៤/២០១៨ ឥ.ទ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨, ឧបសម្ព័ន្ធកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨, លិខិតរំលឹកឲ្យសងប្រាក់ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៩ និងលិខិតព្រមានឲ្យសងប្រាក់ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩ ឃើញថា ភាគីសហចុងចម្លើយពិតជាមានកំហុសដែលមិនបានអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យា ដែលត្រូវទទួលខុសត្រូវលើសំណងនៃការខូចខាតរបស់ដើមចោទរួមនឹងសេវាកម្មផ្លូវច្បាប់។

## ខ-ការវិនិច្ឆ័យចំពោះការទាមទារ

ខ-១-ដើមចោទប្តឹងទាមទារឲ្យសហចុងចម្លើយសងប្រាក់ដើមចំនួន ៣០.៤៩៦,១១$(សាមសិបពាន់បួនរយកៅសិបប្រាំមួយដុល្លារអាមេរិក និងដប់មួយសេន)

តាមរយៈកិច្ចសន្យាខ្ចីបរិភោគលេខ ៣៩៤/២០១៨ ឥ.ទ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ ឃើញថា ភាគីដើមចោទជាអ្នកឲ្យខ្ចី និងភាគីសហចុងចម្លើយជាអ្នកខ្ចី បានព្រមព្រៀងគ្នាចុះកិច្ចសន្យាខ្ចីបរិភោគនូវប្រាក់ចំនួន ៣៥.០០០$(សាមសិបប្រាំពាន់ដុល្លារអាមេរិក) ដោយខ្ចីក្នុងរយៈពេល ៦០(ហុកសិប)ខែ គឺសងរំលស់ប្រាក់ដើម និងការប្រាក់តាមតារាងរំលស់ប្រាក់ដើម និងការប្រាក់។ សហចុងចម្លើយសងប្រាក់ដើមបានមួយចំនួនធ្វើឲ្យប្រាក់ដើមដែលសហចុងចម្លើយនៅជំពាក់មានចំនួន ៣០.៤៩៦,១១$(សាមសិបពាន់បួនរយកៅសិបប្រាំមួយដុល្លារអាមេរិក និងដប់មួយសេន)។

តាមអង្គហេតុដែលបានលើកឡើងខាងលើរបស់អ្នកតំណាងដោយអាណត្តិឲ្យដើមចោទ, ការលើកឡើងរបស់សហចុងចម្លើយ និងតាមការពិនិត្យភស្តុតាងរួមមានៈ កិច្ចសន្យាខ្ចីបរិភោគលេខ ៣៩៤/២០១៨ ឥ.ទ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨, កិច្ចសន្យាបង្កើតសិទ្ធិលើបញ្ចាំ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨, តារាងរំលស់ប្រាក់ដើម និងការប្រាក់ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២០, តារាងរបាយការណ៍បំណុល ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២១ និងការអះអាងទទួលស្គាល់របស់សហចុងចម្លើយ តុលាការពិនិត្យឃើញថា ដើមចោទ និងចុងចម្លើយពិតជាបានព្រមព្រៀងគ្នាបង្កើតកិច្ចសន្យាខ្ចីបរិភោគ ស្របតាមបញ្ញត្តិមាត្រា ៥៧៨ និងមាត្រា៥៧៩ នៃក្រមរដ្ឋប្បវេណី។ តាមរយៈកិច្ចសន្យាខ្ចីបរិភោគនេះដែរ ដើមចោទ និងសហចុងចម្លើយក៏បានព្រមព្រៀងគ្នា ដែលអនុញ្ញាតឲ្យដើមចោទអាចទាមទារឲ្យសហចុងចម្លើយសងប្រាក់មុនពេលកំណត់បានករណីដែលសហចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ច ស្របតាមបញ្ញត្តិមាត្រា ៣៣១ ចំណុច ឃ, មាត្រា ៣៩១ និងមាត្រា ៤៤៣ នៃក្រមរដ្ឋប្បវេណី។ ដូចនេះ តុលាការអាចជឿបានថា សហចុងចម្លើយពិតជានៅជំពាក់ប្រាក់ដើមរបស់ដើមចោទប្រាកដមែន។

ហេតុដូចនេះ តុលាការគប្បីសម្រេចទទួលស្គាល់តាមការទាមទាររបស់ដើមចោទ និងគប្បីសម្រេច



Scanned with CamScanner

បង្គាប់ឲ្យចុងចម្លើយសងប្រាក់ដើមចំនួន ៣០.៤៩៦,១១$(សាមសិបពាន់បួនរយកៅសិបប្រាំមួយដុល្លារអាមេរិក និងដប់មួយសេន) ទៅឲ្យដើមចោទ។

ខ-២-ដើមចោទប្តឹងទាមទារឲ្យសហចុងចម្លើយសងការប្រាក់តាមអត្រា ១២%(ដប់ពីរភាគរយ)ក្នុងមួយឆ្នាំ នៃប្រាក់ដើមចំនួន ៣០.៤៩៦,១១$(សាមសិបពាន់បួនរយកៅសិបប្រាំមួយដុល្លារអាមេរិក និងដប់មួយសេន) គិតចាប់ពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ រហូតដល់ថ្ងៃសងរួចគ្រប់ចំនួន

ដើមចោទអះអាងថា តាមកិច្ចសន្យាខ្ចីបរិភោគលេខ ៣៩៤/២០១៨ ឥ.ទ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ នៅត្រង់ប្រការ២ ចំណុច២.៣ និងឧបសម្ព័ន្ធនៃកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ សហចុងចម្លើយបានព្រមព្រៀងគ្នាកំណត់យកការប្រាក់តាមអត្រា ១២%(ដប់ពីរភាគរយ)ក្នុងមួយឆ្នាំ ហើយចាប់ពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ សហចុងចម្លើយបានខកខានក្នុងការបង់ការប្រាក់។

យោងតាមមាត្រា ៥៨៣, មាត្រា ៥៨៤ និងមាត្រា ៥៨៥ នៃក្រមរដ្ឋប្បវេណី, ប្រកាសលេខ ១២៨ កយ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិត របស់ក្រសួងយុត្តិធម៌ និងប្រកាស ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧ ស្តីពីការកំណត់ពិដានអត្រាការប្រាក់ឥណទាន ដែលអនុញ្ញាតឲ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុមានសិទ្ធិក្នុងការកំណត់អត្រាការប្រាក់លើប្រាក់ឥណទានមិនឲ្យលើសពី ១៨%(ដប់ប្រាំបីភាគរយ)ក្នុងមួយឆ្នាំសម្រាប់គ្រប់ឥណប្រតិទាននៃឥណទាន។

តុលាការយល់ឃើញថា សហចុងចម្លើយពិតជាបានព្រមព្រៀងគ្នាជាមួយដើមចោទ ក្នុងការកំណត់ការប្រាក់តាមអត្រា ១២%(ដប់ពីរភាគរយ)ក្នុងមួយឆ្នាំ តាមកិច្ចសន្យាខ្ចីបរិភោគលេខ ៣៩៤/២០១៨ ឥ.ទ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ ប្រាកដមែន ដោយការប្រាក់នេះមិនបានលើសពីការកម្រិតដែលច្បាប់បានកំណត់នោះទេ។ តាមរយៈកិច្ចសន្យាខាងលើនេះដែរ ឃើញថាអំឡុងពេលក្នុងការអនុវត្តកាតព្វកិច្ចរបស់សហចុងចម្លើយត្រូវបានបញ្ចប់នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៤។ម្យ៉ាងទៀតតាមតារាងរំលស់ប្រាក់ដើម និងការប្រាក់ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២១ និងតារាងរបាយការណ៍បំណុល ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២១ ក៏បានបញ្ជាក់ពីការព្រមព្រៀងរវាងដើមចោទ និងសហចុងចម្លើយក្នុងការកំណត់អត្រាការប្រាក់ និងបានខកខានបង់ការប្រាក់ឲ្យដើមចោទ ចាប់តាំងពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ មក។

ហេតុដូច្នេះ តុលាការគប្បីសម្រេចបង្គាប់ឲ្យសហចុងចម្លើយសងការប្រាក់តាមអត្រា ១២%(ដប់ពីរភាគរយ)ក្នុងមួយឆ្នាំ នៃប្រាក់ដើមចំនួន ៣០.៤៩៦,១១$(សាមសិបពាន់បួនរយកៅសិបប្រាំមួយដុល្លារអាមេរិក និងដប់មួយសេន) គិតចាប់ពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៤ ទៅឲ្យដើមចោទ។

ខ-៣-ដើមចោទប្តឹងទាមទារឲ្យសហចុងចម្លើយបង់ការប្រាក់សំណងការខូចខាត (ការប្រាក់ពិន័យ) តាមអត្រាស្មើនឹង២(ពីរ)ដងនៃអត្រាការប្រាក់ដែលមានចែងក្នុងកិច្ចសន្យាខ្ចីបរិភោគលេខ ៣៩៤/២០១៨ ឥ.ទ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ នៃប្រាក់ដើមចំនួន ៣០.៤៩៦,១១$(សាមសិបពាន់បួនរយកៅសិបប្រាំមួយដុល្លារអាមេរិក និងដប់មួយសេន) គិតចាប់ពីថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៩ រហូតដល់ថ្ងៃសងរួចគ្រប់ចំនួន

ដើមចោទបានអះអាងថា សហចុងចម្លើយមិនអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យា ទើបទាមទារឲ្យសហចុងចម្លើយបង់ប្រាក់សំណងការខូចខាត(ការប្រាក់ពិន័យ) តាមឧបសម្ព័ន្ធនៃកិច្ចសន្យាខ្ចីបរិភោគលេខ



Scanned with CamScanner

៣៩៤/២០១៨ ឥ.ទ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ ត្រង់ចំណុច៧.៥ និងចំណុច៨.៣ ដែលបានចែងថា សំណងនៃការខូចខាតត្រូវបង់តាមអត្រា ១២%(ដប់ពីរភាគរយ)ក្នុងមួយឆ្នាំ នៃប្រាក់ដើម។

យោងតាមមាត្រា ៣៩៨ និងមាត្រា ៤០៣ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី ឃើញថា សហចុងចម្លើយជាអ្នកមានកំហុសក្នុងការមិនបានអនុវត្តកាតព្វកិច្ច ហេតុនេះ សហចុងចម្លើយមិនអាចរួចផុតពីការបង់ការប្រាក់ក្នុងអំឡុងពេលនៃការយឺតយ៉ាវនោះបានទេ។ ការប្រាក់ក្នុងអំឡុងពេលនៃការយឺតយ៉ាវនោះ ត្រូវគណនាតាមអត្រាការប្រាក់ដែលច្បាប់កំណត់បើអត្រាការប្រាក់ក្នុងកិច្ចសន្យាខ្ពស់ជាងអត្រាការប្រាក់ ដែលច្បាប់បានកំណត់នោះ ត្រូវគណនាតាមអត្រាការប្រាក់ក្នុងកិច្ចសន្យា។ ម្យ៉ាងទៀត បើពិនិត្យទៅតាមកិច្ចសន្យាខ្ចីបរិភោគលេខ ៣៩៤/២០១៨ ឥ.ទ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ បានបញ្ជាក់អំពីការកំណត់ជាមុននូវចំនួននៃសំណងការខូចខាតតាមអត្រាស្មើនឹង២(ពីរ)ដងនៃអត្រាការប្រាក់ នៃប្រាក់ដើម ក្នុងករណីដែលមានការយឺតយ៉ាវក្នុងការសងប្រាក់ទៅតាមតារាងរំលស់ប្រាក់ដើម និងការប្រាក់។ ហើយម្យ៉ាងទៀត បើតាមលិខិតរំលឹកឲ្យសងប្រាក់ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៩ និងលិខិតព្រមានឲ្យសងប្រាក់ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩ ដើមចោទបានជូនដំណឹងទៅឲ្យសហចុងចម្លើយដើម្បីធ្វើការទូទាត់ប្រាក់ដែលនៅសល់ ប៉ុន្តែសហចុងចម្លើយនៅតែមានការយឺតយ៉ាវក្នុងការសងប្រាក់ទៅឲ្យដើមចោទដដែល។ ដូចនេះ ភាគីសហចុងចម្លើយជាអ្នកមានកំហុសដែលមិនបានអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យាខ្ចីបរិភោគលេខ ៣៩៤/២០១៨ ឥ.ទ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨។

ហេតុដូច្នេះ តុលាការគប្បីសម្រេចទទួលស្គាល់តាមការទាមទាររបស់ដើមចោទ ដោយបង្គាប់ឲ្យសហចុងចម្លើយបង់ការប្រាក់សំណងការខូចខាត(ការប្រាក់ពិន័យ)តាមអត្រាស្មើនឹង២(ពីរ)ដង នៃអត្រាការប្រាក់ដែលមានចែងក្នុងកិច្ចសន្យាខ្ចីបរិភោគលេខ ៣៩៤/២០១៨ ឥ.ទ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ លើប្រាក់ដើមចំនួន ៣០.៤៩៦,១១$(សាមសិបពាន់បួនរយកៅសិបប្រាំមួយដុល្លារអាមេរិក និងដប់មួយសេន) គិតចាប់ពីថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៩ រហូតដល់ថ្ងៃសងរួចគ្រប់ចំនួន។

**ខ-៤-ដើមចោទប្តឹងទាមទារឲ្យសហចុងចម្លើយបង់ប្រាក់សេវាកម្មច្បាប់ និងការខាតបង់ពេលវេលាចំនួន ៥.០០០$(ប្រាំពាន់ដុល្លារអាមេរិក)**

យោងតាមកិច្ចសន្យាខ្ចីបរិភោគលេខ ៣៩៤/២០១៨ ឥ.ទ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ និងឧបសម្ព័ន្ធនៃកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ នៅត្រង់ចំណុច៧.៥ និងចំណុច៨.៣ បានកំណត់ថា ករណីមានបណ្តឹងទាមទារ សហចុងចម្លើយយល់ព្រមទទួលខុសត្រូវលើការចំណាយសម្រាប់នីតិវិធីនៃបណ្តឹង និងសោហ៊ុយចំណាយមេធាវី រួមទាំងសោហ៊ុយចំណាយផ្សេងៗទៀតទាំងអស់ជូនដើមចោទក្នុងករណីសហចុងចម្លើយបំពានកិច្ចសន្យា។

តុលាការយល់ឃើញថា សហចុងចម្លើយ គឺពិតជាមានកំហុសដែលមិនបានអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យាខ្ចីបរិភោគលេខ ៣៩៤/២០១៨ ឥ.ទ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ ដែលត្រូវទទួលខុសត្រូវលើសំណងនៃការខូចខាតរបស់ដើមចោទ ដែលក្នុងនោះរួមមានការប្រើប្រាស់សោហ៊ុយចំណាយផ្លូវច្បាប់ដើម្បីដោះស្រាយបំណុលជាមួយសហចុងចម្លើយ។

ដូចនេះ យោងតាមមាត្រា ៤០០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី តុលាការទទួលស្គាល់ថា ការចំណាយផ្សេងៗរបស់ដើមចោទដែលកើតចេញពីការមិនអនុវត្តកាតព្វកិច្ចរបស់សហចុងចម្លើយ គឺជាសំណង



Scanned with CamScanner

នៃការខូចខាត ដែលគប្បីតុលាការសម្រេចឲ្យសហចុងចម្លើយបង់ប្រាក់ដែលជាសំណងនៃការខូចខាត ឲ្យទៅដើមចោទដោយពិចារណាទៅលើស្ថានភាពសេដ្ឋកិច្ច ទំហំនៃការខូចខាត និងជីវភាពរបស់សហចុងចម្លើយស្របតាមបញ្ញត្តិមាត្រា ៤០១ នៃក្រមរដ្ឋប្បវេណី។

**ខ-៥-ដើមចោទប្តឹងទាមទារឲ្យសហចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី**

ដោយសារសហចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យា និងជាអ្នកមានកំហុស ដោយយោងតាមបញ្ញត្តិមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី បន្ទុកនៃប្រាក់ប្រដាប់ក្តីជារបស់ភាគីចាញ់ក្តី។

ហេតុដូច្នេះ គប្បីតុលាការសម្រេចឲ្យភាគីដែលចាញ់ក្តីជាអ្នកទទួលបន្ទុកលើប្រាក់ប្រដាប់ក្តី។

**ខ-៦-ដើមចោទប្តឹងទាមទារឲ្យតុលាការចេញសាលក្រមមានអានុភាពអនុវត្ត ជាបណ្តោះអាសន្ននៅត្រង់ចំណុចទី១, ទី២ និងទី៣**

ដោយសារតែសហចុងចម្លើយមិនអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យា និងដើម្បីងាយស្រួលនៅក្នុងការចាត់ចែងនូវនីតិវិធីបន្តទៀត ម្យ៉ាងទៀតកិច្ចសន្យាខ្ចីបរិភោគលេខ ៣៩៤/២០១៨ ឥ.ទ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ មានភាពច្បាស់លាស់ និងដើម្បីកុំឲ្យមានការអូសបន្លាយនីតិវិធីតទៅមុខទៀត។ តុលាការយល់ឃើញថា ការប្រកាសសាលក្រមឲ្យអនុវត្តជាបណ្តោះអាសន្ននោះ ជាការចាំបាច់ចំពោះការទាមទារដែលមានសិទ្ធិលើទ្រព្យសម្បត្តិ ដូច្នេះ ដើម្បីជៀសវាងការអូសបន្លាយពេលវេលា និងជាការចាំបាច់តាមបញ្ញត្តិមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការគប្បីចេញសាលក្រមសម្រេចប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្នលើការទាមទារចំណុចទី១ និងចំណុចទី២ របស់ដើមចោទនៅក្នុងសេចក្តីសម្រេចនៃសាលក្រមនេះ។ ដោយឡែក ការទាមទារឲ្យតុលាការចេញសាលក្រមប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្នលើចំណុចផ្សេងទៀតនោះ តុលាការយល់ឃើញថា តាមមាត្រា ៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី សេចក្តីសម្រេចដែលប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន គឺមានអានុភាពយកទៅអនុវត្តដូចជាសាលក្រម ឬសាលដីកាស្ថាពរដែរ។ ដូចនេះ ក្នុងការសម្រេចសេចក្តីដែលភ្ជាប់នឹងការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ននោះ ត្រូវតែគិតពិចារណាឲ្យបានហ្មត់ចត់បំផុត ម្យ៉ាងទៀត ក្នុងករណីមានបណ្តឹងឧបាស្រ័យចំពោះសេចក្តីសម្រេចនៅក្នុងសាលក្រមទៅតុលាការជាន់ខ្ពស់នោះ អាចនឹងមានការផ្លាស់ប្តូរនៅត្រង់ចំណុចណាមួយក្នុងសេចក្តីសម្រេចឲ្យអនុវត្តជាបណ្តោះអាសន្ន ជាហេតុធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីទាំងសងខាង។ ហេតុដូច្នេះ តុលាការគប្បីសម្រេចច្រានចោលការទាមទារត្រង់ចំណុចទី៣ របស់ដើមចោទខាងលើ។

សហចុងចម្លើយឈ្មោះ [redacted] រ៉ាណូ ក្រឡាបញ្ជីបានបញ្ជូនដីកាកោះត្រឹមត្រូវតាមនីតិវិធីរួចហើយ ដោយធ្វើការបញ្ជូនដីកាកោះ និងសេចក្តីថ្លែងការណ៍របស់ដើមចោទ ឲ្យដល់សហចុងចម្លើយឈ្មោះ [redacted] រ៉ាណូ រួចរាល់ដោយឈ្មោះ [redacted] ស្រីទូត ជាអ្នកទទួលដីកាកោះ ហើយឈ្មោះនេះបានបញ្ជាក់ថា នឹងជូនដំណឹងអំពីដីកាកោះធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ដល់សហចុងចម្លើយរួចហើយ ប៉ុន្តែសហចុងចម្លើយនៅតែអវត្តមាន។ ម្យ៉ាងទៀត នៅពេលធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់សហចុងចម្លើយឈ្មោះ ហ៊ិន ស្រីតូច បានបញ្ជាក់ថាសហចុងចម្លើយឈ្មោះ [redacted] រ៉ាណូ បានដឹងពីការធ្វើនីតិវិធីនេះហើយ ប៉ុន្តែគាត់មិនបានចូលរួមនោះទេ។ យោងតាមមាត្រា ២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ការណ៍ដែលសហចុងចម្លើយដែលអវត្តមានបានសារភាពតាមសេចក្តីថ្លែងការណ៍របស់ដើមចោទ ដែលទាក់ទាងនឹងអង្គហេតុ ដែលគប្បីសម្រេចទទួលស្គាល់តាមការទាមទាររបស់ដើមចោទ។

## សេចក្តីសម្រេចបញ្ចប់

១-បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ [redacted] ស្រីតួច និងឈ្មោះ [redacted] វ៉ាណូ សងប្រាក់ដើមសរុបចំនួន ៣០.៤៩៦,១១$(សាមសិបពាន់បួនរយកៅសិបប្រាំមួយដុល្លារអាមេរិក និងដប់មួយសេន) ឲ្យទៅដើមចោទ ធនាគារ[redacted] ដែលមានឈ្មោះ [redacted] វដ្ឋា ជាតំណាង។

២-បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ [redacted] ស្រីតួច និងឈ្មោះ [redacted] វ៉ាណូ បង់ការប្រាក់តាមអត្រា ១២%(ដប់ពីរភាគរយ)ក្នុងមួយឆ្នាំ នៃប្រាក់ដើមចំនួន ៣០.៤៩៦,១១$(សាមសិបពាន់បួនរយកៅសិបប្រាំមួយដុល្លារអាមេរិក និងដប់មួយសេន) គិតចាប់ពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៤ ឲ្យទៅដើមចោទ ធនាគារ[redacted]ដែលមានឈ្មោះ [redacted] វដ្ឋា ជាតំណាង។

៣-បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ [redacted] ស្រីតួច និងឈ្មោះ [redacted] វ៉ាណូ បង់ការប្រាក់ពិន័យតាមអត្រា ស្មើនឹង២(ពីរ)ដងនៃអត្រាការប្រាក់ដែលមានចែងនៅក្នុងកិច្ចសន្យាខ្ចីបរិភោគលេខ ៣៩៤/២០១៨ ឥ.ទ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ នៃប្រាក់ដើមចំនួន ៣០.៤៩៦,១១$(សាមសិបពាន់បួនរយកៅសិបប្រាំមួយដុល្លារអាមេរិក និងដប់មួយសេន) គិតចាប់ពីថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៩ រហូតដល់ថ្ងៃសងរួចគ្រប់ចំនួន ឲ្យទៅដើមចោទ ធនាគារ[redacted]ដែលមានឈ្មោះ [redacted] វដ្ឋា ជាតំណាង។

៤-បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ [redacted] ស្រីតួច និងឈ្មោះ [redacted] វ៉ាណូ បង់សំណងការខូចខាត និងសេវាកម្មច្បាប់ចំនួន ៣.០០០.០០០៛(បីលានរៀល) ទៅឲ្យដើមចោទ ធនាគារ[redacted] ដែលមានឈ្មោះ [redacted]ដ្ឋា ជាតំណាង ការទាមទារលើសពីនេះបដិសេធចោល។

៥-បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ [redacted] ស្រីតួច និងឈ្មោះ [redacted] វ៉ាណូ ជាអ្នកទទួលបន្ទុកលើប្រាក់ប្រដាប់ក្តី និងប្រាក់បង់ពន្ធផ្សេងៗ។

៦-សាលក្រមនេះប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន ត្រង់ចំណុចទី១ និងចំណុចទី២ នៃសេចក្តីសម្រេចបញ្ចប់ខាងលើ។ ច្រានចោលការទាមទារប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន ត្រង់ចំណុចទី៣។

សាលក្រមនេះ ត្រូវបានប្រកាសនៅសាលសវនាការជាសាធារណៈ នៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១។ ក្នុងករណីភាគីមិនសុខចិត្តនឹងសាលក្រមនេះអាចប្តឹងឧទ្ធរណ៍ ក្នុងអំឡុងពេល ០១(មួយ)ខែ គិតចាប់ពីថ្ងៃទទួលការបញ្ជូនលិខិតសាលក្រមនេះ។

**ចៅក្រម**

ហត្ថលេខា និង ត្រា: [redacted]

---

"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃចន្ទ ១៤រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

សៀមរាប ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រម**

[redacted]



Scanned with CamScanner